# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩ អនក្រ.បក

ជាតិ សាសនា ព្រះមហាក្សត្រ

## អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសហគមន៍ព្រៃឈើ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/ករម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះមានគោលដៅកំណត់វិធានសម្រាប់ការបង្កើត ការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការប្រើប្រាស់ព្រៃសហគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.–**

អនុក្រឹត្យនេះមានគោលបំណងដើម្បី ÷

- អនុវត្តច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើ ដោយសហគមន៍មូលដ្ឋាន
- កំណត់សិទ្ធិ តួនាទី និងភារកិច្ចរបស់អាជ្ញាធរសមត្ថកិច្ចទទួលខុសត្រូវសហគមន៍ព្រៃឈើ របស់សហគមន៍ព្រៃឈើ និង អ្នកពាក់ព័ន្ធផ្សេងៗទៀត ដែលចូលរួមក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ដំណើរការនៃការរៀបចំសម្រាប់សហគមន៍ព្រៃឈើធ្វើការគ្រប់គ្រង ប្រើប្រាស់ និងទទួលផលប្រយោជន៍ពីធនធានព្រៃឈើ ថែរក្សាវប្បធម៌ ប្រពៃណី និងកែលំអជីវភាពរស់នៅ
- ធានាសិទ្ធិប្រើប្រាស់ដល់សហគមន៍ព្រៃឈើនៅក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍
- គាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ និង ការគ្រប់គ្រងតាមនយោបាយវិមជ្ឈការ
- ផ្តល់នូវមធ្យោបាយដែលមានប្រសិទ្ធភាពដល់សហគមន៍ព្រៃឈើ ដើម្បីចូលរួមក្នុងការដាំដើមឈើ ស្តារព្រៃឈើឡើងវិញ និងអភិរក្សធនធានធម្មជាតិ ព្រៃឈើ និងសត្វព្រៃ
- ឱ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹង និងទទួលស្គាល់កាន់តែច្បាស់នូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានព្រៃឈើ តាមរយៈការចូលរួមគ្រប់គ្រង និងការពារធនធានទាំងនោះដោយផ្ទាល់
- ផ្តល់ក្របខណ្ឌច្បាប់សម្រាប់បង្កភាពងាយស្រួល ជូនដល់ប្រជាពលរដ្ឋខ្មែរនៅតាមមូលដ្ឋានក្នុងការបង្កើតសហគមន៍ព្រៃឈើ ដើម្បីរួមចំណែកក្នុងការចូលរួមគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

**មាត្រា ៣.–**

ព្រៃសហគមន៍ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។
ព្រំប្រទល់ព្រៃសហគមន៍នីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលព្រៃឈើ។

**មាត្រា ៤.–**

អំណាចដឹកនាំ និងគ្រប់គ្រងសហគមន៍ព្រៃឈើ បានមកពីការបោះឆ្នោតរបស់សមាជិកសហគមន៍ ។

**មាត្រា ៥.–**

វាក្យស័ព្ទសំខាន់ៗ សម្រាប់ប្រើក្នុងអនុក្រឹត្យនេះមាន ៖

១. **ការប្រើប្រាស់ប្រកបដោយនិរន្តរភាព:** សំដៅដល់ការប្រើប្រាស់ធនធានព្រៃឈើ ដោយធានារក្សានូវធនធានព្រៃឈើនោះសម្រាប់ជាផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ ។

២. **ការប្រើប្រាស់ជាប្រពៃណី:** សំដៅដល់ការប្រើប្រាស់ធនធានព្រៃឈើរបស់សហគមន៍មូលដ្ឋាន ដោយនិរន្តរភាពក្នុងគោលបំណងចិញ្ចឹមជីវិត ដូចមានចែងនៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីព្រៃឈើ ។

៣. **កិច្ចព្រមព្រៀងព្រៃសហគមន៍:** សំដៅដល់ការព្រមព្រៀងមួយជាលាយលក្ខណ៍អក្សររវាងសហគមន៍ព្រៃឈើ និង នាយខណ្ឌរដ្ឋបាលព្រៃឈើដែលបានផ្តល់ និងធានាសិទ្ធិរបស់សហគមន៍ព្រៃឈើក្នុងតំបន់ជាក់លាក់ណាមួយ សម្រាប់ការរៀបចំការពារ ប្រើប្រាស់ និង ទទួលផលប្រយោជន៍ពីធនធានព្រៃឈើប្រកបដោយនិរន្តរភាព ។

៤. **បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ:** សំដៅដល់លក្ខខណ្ឌ ដែលបានអនុម័តដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ស្តីពីការប្រតិបត្តិផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ រួមមានចំនួនសមាជិកវត្តមានចាំបាច់ អាណត្តិរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ចំនួនសមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និង វិធីសាស្ត្ររៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

៥. **ផែនការគ្រប់គ្រងព្រៃសហគមន៍:** សំដៅដល់ឯកសារមួយ ដែលបានរៀបចំឡើងដោយសហគមន៍ព្រៃឈើ និងមានការឯកភាពពីរដ្ឋបាលព្រៃឈើ ដោយមានការវាយតំលៃហេតុប៉ះពាល់សង្គម និងបរិស្ថាន និង បញ្ជាក់លំអិតអំពីនីតិវិធីបទបញ្ជា និងវិធានការពាក់ព័ន្ធនឹងការរៀបចំប្រើប្រាស់ព្រៃសហគមន៍ប្រកបដោយនិរន្តរភាព ។

៦. **ព្រៃសហគមន៍:** សំដៅដល់ចំការព្រៃដាំរបស់សហគមន៍ ឬព្រៃរបស់រដ្ឋ ដែលបានព្រមព្រៀងផ្តល់សិទ្ធិជូនសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងឬក្បែរព្រៃធ្វើការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើនោះប្រកបដោយនិរន្តរភាពរវាងរដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋាន ។

៧. **រដ្ឋបាលព្រៃឈើ:** សំដៅដល់អាជ្ញាធររដ្ឋាភិបាលគ្រប់ថ្នាក់ដែលមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើស្របតាមគោលនយោបាយព្រៃឈើជាតិ និងអនុវត្តតាមច្បាប់ស្តីពីព្រៃឈើ ។

៨. **លក្ខន្តិកៈសហគមន៍ព្រៃឈើ:** សំដៅដល់បទដ្ឋាន ដែលបានអនុម័តដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ស្តីពីការប្រើប្រាស់ និងគ្រប់គ្រងព្រៃសហគមន៍ ស្របទៅតាមផែនការគ្រប់គ្រងព្រៃសហគមន៍ រួមមានសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកសហគមន៍ព្រៃឈើ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ក្រៅពីសមាជិកសហគមន៍ព្រៃឈើ កម្រៃពីការប្រើប្រាស់ ការបែងចែកផលប្រយោជន៍ ការធ្វើរបាយការណ៍ និងការពិន័យចំពោះបទល្មើសផ្សេងៗ ។

៩. **សហគមន៍:** សំដៅដល់ក្រុមអ្នកស្រុកនៅក្នុងភូមិមួយ ឬច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការចាប់អារម្មណ៍រួមលើបញ្ហាសង្គម បរិស្ថាន វប្បធម៌ ប្រពៃណី និង សេដ្ឋកិច្ច ក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៃតំបន់មួយ ដែលពួកគាត់រស់នៅក្នុងឬក្បែរតំបន់នោះ ក្នុងគោលបំណងចិញ្ចឹមជីវិត និងកែលំអជីវភាពរស់នៅ ។

១០. **សហគមន៍មូលដ្ឋាន:** សំដៅដល់សហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកស្រុកដែលមានលំនៅដើមកំណើតក្នុងភូមិមួយ ឬច្រើន ស្ថិតនៅក្នុងឬក្បែរតំបន់ព្រៃឈើរដ្ឋ ដែលមានប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនា វប្បធម៌ និងរស់នៅចិញ្ចឹមជីវិតដោយពឹងអាស្រ័យទៅលើការរុករកផល អនុផលព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើទាំងនោះជាមូលដ្ឋាន ។

១១. **សហគមន៍ព្រៃឈើ:** សំដៅដល់សហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំជាក្រុមក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ។

១២. **ស្ថាប័នពាក់ព័ន្ធ:** សំដៅដល់អង្គភាពរដ្ឋ ដែលចូលរួមគាំទ្រ និងផ្តល់ភាពងាយស្រួល ឬ វិភាគទាន តែមិនមានភារកិច្ចក្នុងការសម្រេចលើកិច្ចព្រមព្រៀងព្រៃសហគមន៍ លើផែនការគ្រប់គ្រងព្រៃសហគមន៍ជាមួយសហគមន៍ព្រៃឈើ និង ធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃទេ ។

១៣. **អត្រាកម្រិតប្រមូលផលប្រកបដោយនិរន្តរភាព:** សំដៅដល់បរិមាណធនធានព្រៃឈើប្រមូលដោយសហគមន៍ព្រៃឈើក្នុងអំឡុងពេលជាក់លាក់មួយ ដែលបានកំណត់ដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងបានឯកភាពដោយរដ្ឋបាលព្រៃឈើ ផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

១៤. **អ្នកប្រើប្រាស់ព្រៃសហគមន៍ក្រៅពីសមាជិកសហគមន៍ព្រៃឈើ:** សំដៅដល់បុគ្គល ដែលមិនមែនជាសមាជិកនៅក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ ប៉ុន្តែអាចប្រើប្រាស់ព្រៃសហគមន៍ឱ្យស្របទៅតាមផែនការគ្រប់គ្រងព្រៃសហគមន៍ និង លក្ខន្តិកៈសហគមន៍ព្រៃឈើ ។

## ជំពូកទី ២
## ការបង្កើតសហគមន៍ព្រៃឈើ

**មាត្រា ៦.-**

សហគមន៍ព្រៃឈើអាចផ្តួចផ្តើម និងសុំបង្កើតឡើងដោយសហគមន៍មូលដ្ឋាន ឬ រដ្ឋបាលព្រៃឈើ ។ ការបង្កើតសហគមន៍ព្រៃឈើ របស់សហគមន៍មូលដ្ឋានត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមករដ្ឋបាលព្រៃឈើ ។

**មាត្រា ៧.-**

រដ្ឋបាលព្រៃឈើនៅថ្នាក់មូលដ្ឋានត្រូវសិក្សាវាយតម្លៃ ព្រមទាំងវិភាគលើតម្រូវការ និង បញ្ហាជួបប្រទះរបស់សហគមន៍មូលដ្ឋាន ដែលស្នើសុំបង្កើតសហគមន៍ព្រៃឈើនោះ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៨.-**

ក្រោយពីបានវិភាគលើតម្រូវការ បញ្ហាជួបប្រទះ និងមានការយល់ព្រមពីរដ្ឋបាលព្រៃឈើមក សហគមន៍មូលដ្ឋាននៅក្នុងតំបន់នោះត្រូវចូលរួមបង្កើតគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដោយមានការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី ៣
## តួនាទី ភារកិច្ច និង សិទ្ធិរបស់សហគមន៍ព្រៃឈើ

**មាត្រា ៩.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងចូលជាសមាជិកសហគមន៍ព្រៃឈើ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- រស់នៅក្នុងសហគមន៍ដែលបានកំណត់នៅក្នុងចំណុច ៩ នៃមាត្រា៥ របស់អនុក្រឹត្យនេះ
- មានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំឡើង ។ បុគ្គលម្នាក់អាចជាសមាជិកក្នុងសហគមន៍ព្រៃឈើតែមួយគត់ នៃសហគមន៍ដែលខ្លួនរស់នៅ ។

**មាត្រា ១០.-**

តួនាទី ភារកិច្ចរបស់សមាជិកសហគមន៍ព្រៃឈើគឺ ÷

- អនុវត្តតាមការណែនាំរបស់រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមរៀបចំ និងអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ កិច្ចព្រមព្រៀងព្រៃសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ស្របតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមគ្រប់គ្រងធនធានព្រៃឈើស្របតាមលក្ខន្តិកៈសហគមន៍ព្រៃឈើ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ
- ចូលរួមបង្កើតឱ្យមានការបែងចែកផលប្រយោជន៍ ដែលទទួលបានពីព្រៃសហគមន៍
- ចូលរួមត្រួតពិនិត្យការប្រើប្រាស់ធនធានព្រៃសហគមន៍របស់អ្នកប្រើប្រាស់ព្រៃសហគមន៍ក្រៅពីសមាជិកសហគមន៍ព្រៃឈើ

- ចូលរួមថែរក្សា ការពារ និងដាំដុះព្រៃឈើ ដើម្បីធានានិរន្តរភាពធនធានព្រៃឈើ និងបរិស្ថាន ។

**មាត្រា ១១.–**

សិទ្ធិប្រើប្រាស់របស់សមាជិកសហគមន៍ព្រៃឈើមាន ÷

- សិទ្ធិប្រើប្រាស់ជាប្រពៃណី ដូចមានចែងនៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីព្រៃឈើ

- សិទ្ធិក្នុងការដោះដូរ កែច្នៃ ដឹកជញ្ជូន និងលក់អនុផលព្រៃឈើ ដូចមានចែងនៅក្នុងមាត្រា៤០ កថាខ័ណ្ឌ ២ ចំណុចទី៥ នៃច្បាប់ស្តីពីព្រៃឈើ

- សិទ្ធិអាចបន្តអនុវត្តកសិកម្មពនេចរមានលក្ខណៈជាប្រពៃណីក្នុងរយៈពេលមួយជាក់លាក់ ដោយបានកំណត់នៅក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍ ស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពីព្រៃឈើ

- សិទ្ធិក្នុងការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចទាំងឡាយណា ដែលប៉ះពាល់សិទ្ធិរបស់សហគមន៍ព្រៃឈើ

- សិទ្ធិដែលបានផ្តល់ឱ្យនៅក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ក្នុងតំបន់ជាក់លាក់ណាមួយ ហើយត្រូវធានាបាននូវការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

**មាត្រា ១២.–**

សហគមន៍ដែលស្ថិតនៅក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ អាចប្រមូលផល អនុផលព្រៃឈើ កែច្នៃ ដឹកជញ្ជូន និងលក់ ដោយអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម ÷

- ការប្រមូលផលឈើដើម្បីលក់ ឬដោះដូរ ត្រូវហាមឃាត់ក្នុងរយៈពេលប្រាំ(០៥)ឆ្នាំដំបូង នៅពេលទទួលបានការឯកភាពលើផែនការគ្រប់គ្រងព្រៃសហគមន៍។ ប្រសិនបើសហគមន៍ព្រៃឈើបាននិងកំពុងអនុវត្តជាមួយផែនការគ្រប់គ្រងព្រៃសហគមន៍មុនអនុក្រឹត្យនេះចូលជាធរមាន ការហាមឃាត់ប្រមូលផលឈើត្រូវគិតចាប់តាំងពីថ្ងៃដែលបានឯកភាពលើផែនការគ្រប់គ្រងព្រៃសហគមន៍

- បង់ថ្លៃសួយសារ និង បុព្វលាភលើផល អនុផលព្រៃឈើតាមការកំណត់ដូចមានចែងក្នុងមាត្រា៥៥ នៃច្បាប់ស្តីពីព្រៃឈើ

- ខ្លឹមសារ និងលក្ខខណ្ឌដែលបានឯកភាពនៅក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍។

ផ្អែកលើកិច្ចព្រមព្រៀងព្រៃសហគមន៍ សហគមន៍ព្រៃឈើមានសិទ្ធិដាំ គ្រប់គ្រង ប្រមូលផល អនុផល និងលក់ឈើប្រភេទផ្សេងៗ ដូចបានឯកភាពនៅក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍។

**មាត្រា ១៣.–**

មិនតម្រូវឱ្យមានលិខិតអនុញ្ញាតចំពោះសកម្មភាពរបស់សហគមន៍ព្រៃឈើ ដែលស្ថិតនៅក្នុងតំបន់សហគមន៍ព្រៃឈើ បានអនុវត្តត្រឹមត្រូវស្របតាមខ្លឹមសារ និងលក្ខខណ្ឌនៃផែនការគ្រប់គ្រងព្រៃសហគមន៍ និងកិច្ចព្រមព្រៀងព្រៃសហគមន៍ ដែលបានឯកភាព ។

មិនតម្រូវឱ្យបង់ថ្លៃសួយសារ និង បុព្វលាភលើការប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីរបស់សហគមន៍ព្រៃឈើ ដែលបានអនុវត្តត្រឹមត្រូវស្របតាមខ្លឹមសារនៃផែនការគ្រប់គ្រងព្រៃសហគមន៍ និងកិច្ចព្រមព្រៀងព្រៃសហគមន៍ដែលបានឯកភាព ។

ថ្លៃសួយសារ និងបុព្វលាភត្រូវបានកំណត់ឡើងដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ ការបែងចែកផលប្រយោជន៍ដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រ ។

**មាត្រា ១៤.-**

អ្នកប្រើប្រាស់ព្រៃសហគមន៍ដែលមិនមែនជាសមាជិកសហគមន៍ព្រៃឈើ អាចមានសិទ្ធិចេញ ចូល និងប្រើប្រាស់ព្រៃសហគមន៍ ដោយត្រូវអនុវត្តឱ្យស្របតាមផែនការគ្រប់គ្រងព្រៃសហគមន៍ និងលក្ខន្តិកៈសហគមន៍ព្រៃឈើ ។

**មាត្រា ១៥.-**

សហគមន៍ព្រៃឈើមិនអាច ÷

- យកព្រៃសហគមន៍ទៅប្រើប្រាស់ក្រោមរូបភាពព្រៃគុបអាជីវកម្ម
- លក់ ឬផ្ទេរសិទ្ធិរបស់ខ្លួន ដែលបានប្រគល់ឱ្យក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍ទៅឱ្យភាគីផ្សេងទៀតបានឡើយ
- ដកហូតផល អនុផលព្រៃឈើលើសពីផែនការគ្រប់គ្រងព្រៃសហគមន៍ ។

## ជំពូកទី ៤

## គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

**មាត្រា ១៦.-**

សហគមន៍ព្រៃឈើនីមួយៗត្រូវដឹកនាំដោយគណៈកម្មការមួយហៅថា គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

**មាត្រា ១៧.-**

សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវជ្រើសរើសចេញពីសមាជិកសហគមន៍ព្រៃឈើ តាមរយៈការបោះឆ្នោតដោយសំងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលមានសម្លេងគាំទ្រ២ភាគ៣ពីសមាជិកសហគមន៍ព្រៃឈើ នាពេលប្រជុំជាសាធារណៈ ។

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ បេក្ខជនដែលទទួលបានសំឡេងឆ្នោតបន្ទាប់ គឺជាអនុប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ និងខណ្ឌរដ្ឋបាលព្រៃឈើ ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ក្នុងការបោះឆ្នោត។ លទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ជាផ្លូវការ ទោះបីអវត្តមាននៃអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ និងខណ្ឌរដ្ឋបាលព្រៃឈើក៏ដោយ ។

**មាត្រា ១៨.-**

សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានចំនួនសេសពីប្រាំ(៥) ទៅដប់មួយ(១១)រូប ស្របតាមការណែនាំរបស់រដ្ឋបាលព្រៃឈើ និងត្រូវលើកទឹកចិត្តឱ្យមានស្ត្រីចូលរួមក្នុងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

**មាត្រា ១៩.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជាសមាជិកនៃសហគមន៍ព្រៃឈើសាមី
- មានសញ្ជាតិខ្មែរពីកំណើត ។

**មាត្រា ២០.-**

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

**មាត្រា ២១.-**

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុម័តលក្ខន្តិកៈសហគមន៍ព្រៃឈើ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ និងមានការជួយសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ និងមានការជួយសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ និងមានជំនួយបច្ចេកទេសពីខណ្ឌរដ្ឋបាលព្រៃឈើ តាមការស្នើសុំ
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលព្រៃឈើ ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍ព្រៃឈើ
- តំណាងឱ្យសហគមន៍ព្រៃឈើក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន

- បើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍ព្រៃឈើ ដោយមានតម្លាភាព និងការទទួលខុសត្រូវ

- ធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍសហគមន៍ព្រៃឈើ ដោយមានការយល់ព្រមពីសមាជិកសហគមន៍ព្រៃឈើភាគច្រើនស្របទៅតាមលក្ខន្តិកៈសហគមន៍ព្រៃឈើ កិច្ចព្រមព្រៀងព្រៃសហគមន៍ និង ផែនការគ្រប់គ្រងព្រៃសហគមន៍

- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានា ដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សមាជិកសហគមន៍ព្រៃឈើ

- រាយការណ៍ និងផ្តល់ពត៌មានជាបន្ទាន់នូវរាល់បទល្មើសព្រៃឈើក្នុងតំបន់ព្រៃសហគមន៍ដល់រដ្ឋបាលព្រៃឈើ ដែលនៅជិតបំផុត

- ធ្វើការអភិរក្ស និងការពារសត្វព្រៃនៅក្នុងព្រៃសហគមន៍

- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋបាលព្រៃឈើ ។

**មាត្រា ២២.-**

មានតែគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើតែមួយគត់ ដែលមានសិទ្ធិដាក់ពាក្យស្នើសុំកិច្ចព្រមព្រៀងព្រៃសហគមន៍ទៅខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីសុំការឯកភាព ។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ អាចស្នើសុំជំនួយបច្ចេកទេសពីខណ្ឌរដ្ឋបាលព្រៃឈើ ឬអ្នកដែលមានជំនាញក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីធ្វើការរៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ ។

## ជំពូកទី ៥
## ស្ថាប័ន និង អាជ្ញាធរសមត្ថកិច្ចទទួលខុសត្រូវ

**មាត្រា ២៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍ព្រៃឈើ ហើយមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ធ្វើជាអាណាព្យាបាលរបស់សហគមន៍ព្រៃឈើ

- ចេញប្រកាសទទួលស្គាល់ បដិសេធ និងរំសាយតំបន់ដែលស្នើសុំបង្កើតសហគមន៍ព្រៃឈើ ដោយរដ្ឋបាលព្រៃឈើ

- ចេញប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ គំរូបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ កិច្ចព្រមព្រៀងព្រៃសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍ តាមរយៈដំណើរការពិគ្រោះយោបល់

- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត លើការអនុវត្ត និងការអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ

- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់សហគមន៍ព្រៃឈើ ។

**មាត្រា ២៤.-**

រដ្ឋបាលព្រៃឈើមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ធ្វើការសិក្សាវាយតម្លៃ និងកំណត់តំបន់ព្រៃឈើសម្រាប់បង្កើតព្រៃសហគមន៍
- ចេញសេចក្ដីសម្រេចទទួលស្គាល់ បដិសេធ និងរំសាយសហគមន៍ព្រៃឈើ
- ពិនិត្យសើរើ និងផ្ដល់ការយល់ព្រមលើកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយសហគមន៍ព្រៃឈើ តាមរយៈនាយខណ្ឌរដ្ឋបាលព្រៃឈើ
- ត្រួតពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងព្រៃសហគមន៍
- រៀបចំគោលការណ៍ណែនាំផ្សេងៗទៀតទាក់ទងនឹងការគ្រប់គ្រងសហគមន៍ព្រៃឈើ ស្របតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ត្រួតពិនិត្យ និងវាយតម្លៃដំណើរការសហគមន៍ព្រៃឈើ
- ជួយសហគមន៍ព្រៃឈើក្នុងការការពារព្រៃអារក្ស និងព្រៃជំនឿសាសនាផ្សេងៗ
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើត និងដំណើរការអនុវត្តកិច្ចព្រមព្រៀងព្រៃសហគមន៍
- សម្របសម្រួលក្នុងការដោះស្រាយទំនាស់នៅពេលមានការស្នើសុំពីសហគមន៍ព្រៃឈើ
- បង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ប័ណ្ណសារសហគមន៍ព្រៃឈើ និងផែនទីព្រៃសហគមន៍
- ផ្ដល់ជំនួយបច្ចេកទេសដល់សហគមន៍ព្រៃឈើ
- ជំរុញឱ្យមានការបណ្ដុះបណ្ដាលដល់រដ្ឋបាលព្រៃឈើនៅតាមមូលដ្ឋាន និងសហគមន៍ព្រៃឈើ ដើម្បីអនុវត្តការងារសហគមន៍ព្រៃឈើ និងធ្វើឱ្យការប្រតិបត្តិអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព
- ជួយផ្ដល់ពត៌មាននិងឯកសារ ដែលពាក់ព័ន្ធនឹងការងារសហគមន៍ព្រៃឈើទៅឱ្យសហគមន៍ព្រៃឈើ
- ជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដូចជាបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ ព្រមទាំងកិច្ចព្រមព្រៀងព្រៃសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍។

## ជំពូកទី ៦

## កិច្ចព្រមព្រៀងព្រៃសហគមន៍

**មាត្រា ២៥.-**

កិច្ចព្រមព្រៀងព្រៃសហគមន៍ ត្រូវភ្ជាប់មកជាមួយនូវ ÷

- ផែនទីបញ្ជាក់ពីតំបន់ស្នើសុំបង្កើតព្រៃសហគមន៍តាមកិច្ចព្រមព្រៀងព្រៃសហគមន៍ ដែលមាននិយាមការច្បាស់លាស់
- បញ្ជីឈ្មោះសមាជិកសហគមន៍ព្រៃឈើ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងលក្ខន្តិកៈសហគមន៍ព្រៃឈើ

- សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងនៃការបង្កើតសហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានព្រៃឈើ ដោយមានការបញ្ជាក់អះអាងអំពីការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព
- បញ្ជីសារពើភ័ណ្ឌធនធានព្រៃឈើសំខាន់ៗមាននៅក្នុងតំបន់ ដែលបានស្នើក្នុងកិច្ចព្រមព្រៀងព្រៃសហគមន៍
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ក្នុងករណីចាំបាច់ ។

**មាត្រា ២៦.-**

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ ត្រូវប្រកាសជូនដំណឹងដោយបិទផ្សាយយ៉ាងតិចសាមសិប(៣០)ថ្ងៃ នៅតាមកន្លែងសាធារណៈនានាដែលងាយមើលឃើញ នៅសាលាឃុំ សង្កាត់ ស្រុក ខណ្ឌ និងខេត្ត ក្រុង មុននឹងដាក់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ជូនខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យ និងសម្រេច ។

ក្នុងករណីមានការទំនាស់កើតឡើងក្នុងអំឡុងពេលប្រកាសជូនដំណឹង ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរស្រុក ខណ្ឌ និងខេត្ត ក្រុង ត្រូវជួយសម្របសម្រួលដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីដោះស្រាយទំនាស់ ឬកែសម្រួលសេចក្តីព្រាងនៃកិច្ចព្រមព្រៀងព្រៃសហគមន៍ តាមការស្នើឡើងដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

នីតិវិធីនៃការរៀបចំកិច្ចព្រមព្រៀងព្រៃសហគមន៍ ត្រូវកំណត់ដោយប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២៧.-**

កិច្ចព្រមព្រៀងព្រៃសហគមន៍មានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ(១៥)ឆ្នាំ ចាប់ពីថ្ងៃឯកភាពដោយនាយខណ្ឌរដ្ឋបាលព្រៃឈើ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់នាយខណ្ឌរដ្ឋបាលព្រៃឈើ រយៈពេលមួយ(០១)ឆ្នាំមុនពេលកិច្ចព្រមព្រៀងផុតសុពលភាព ដើម្បីបន្តកិច្ចព្រមព្រៀងព្រៃសហគមន៍មិនលើសពីរយៈពេលដប់ប្រាំ(១៥)ឆ្នាំជាថ្មី ។

ការសុំបន្តនេះត្រូវបានអនុញ្ញាតជូនតាមរយៈសេចក្តីជូនដំណឹងរបស់ខណ្ឌរដ្ឋបាលព្រៃឈើ ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃមុនថ្ងៃផុតកំណត់នៃកិច្ចព្រមព្រៀងព្រៃសហគមន៍ ។ ខណ្ឌរដ្ឋបាលព្រៃឈើ បញ្ចប់កិច្ចព្រមព្រៀងព្រៃសហគមន៍ ឬមិនផ្តល់ការអនុញ្ញាតឱ្យបន្ត ប្រសិនបើនាយខណ្ឌរដ្ឋបាលព្រៃឈើបានផ្ញើជូនគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើវិញនូវរបាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យ និងវាយតម្លៃរបស់ផ្នែករដ្ឋបាលព្រៃឈើសាមី ដែលមានការចូលរួមជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លើដំណើរការអនុវត្តការគ្រប់គ្រងព្រៃសហគមន៍កន្លងមក ដោយបញ្ជាក់នូវមូលហេតុ និងកស្តុតាងនៃការមិនគោរពតាមកិច្ចព្រមព្រៀងព្រៃសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ។

ករណីខណ្ឌរដ្ឋបាលព្រៃឈើ មិនបានផ្តល់សេចក្តីជូនដំណឹងចំពោះការស្នើសុំបន្តកិច្ចព្រមព្រៀងព្រៃសហគមន៍ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃមុនថ្ងៃផុតសុពលភាព កិច្ចព្រមព្រៀងព្រៃសហគមន៍ត្រូវបានបន្តដោយស្វ័យប្រវត្តិ ។

**មាត្រា ២៨.–**

កិច្ចព្រមព្រៀងព្រៃសហគមន៍ អាចត្រូវបានបញ្ឈប់មុនពេលថ្ងៃកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយ ឬច្រើនដូចខាងក្រោម ៖

១- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ ។

២- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមានការឯកភាពពីរ(២) ភាគបី(៣) ពីសមាជិកសហគមន៍ព្រៃឈើ ។

៣- ការមិនអនុវត្ត ឬអនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងព្រៃសហគមន៍ និងបទប្បញ្ញត្តិនានា ដែលមិនធានាដល់និរន្តរភាពធនធានព្រៃឈើ ។

៤- ការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជានូវគោលបំណងផ្សេងមួយទៀត ដែលបំរើឱ្យប្រយោជន៍សាធារណៈ និងសង្គមច្រើនជាងចំពោះព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីកិច្ចព្រមព្រៀងព្រៃសហគមន៍ត្រូវបានបញ្ឈប់ដោយរាជរដ្ឋាភិបាលក្នុងគោលបំណងផ្សេងទៀត ដែលបំរើឱ្យប្រយោជន៍សាធារណៈ និងសង្គមច្រើនជាងចំពោះព្រះរាជាណាចក្រកម្ពុជា នៅពេលនោះខណ្ឌរដ្ឋបាលព្រៃឈើត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំមួយ(០៦)ខែ មុនការបញ្ឈប់ទៅឱ្យគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដោយបញ្ជាក់ប្រាប់ពីមូលហេតុនៃការបញ្ឈប់នេះ ។ ក្នុងរយៈពេលនេះខណ្ឌរដ្ឋបាលព្រៃឈើត្រូវធ្វើការពិភាក្សាសម្របសម្រួលជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីកំណត់នូវគោលនយោបាយសមស្របចំពោះការបាត់បង់ផលប្រយោជន៍របស់សហគមន៍ ។

## ជំពូកទី ៧
## ផែនការគ្រប់គ្រងព្រៃសហគមន៍

**មាត្រា ២៩.–**

បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងព្រៃសហគមន៍ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ដោយមានការចូលរួមពីសមាជិកសហគមន៍ព្រៃឈើ តាមនីតិវិធីដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើអាចស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ពីរដ្ឋបាលព្រៃឈើ ស្ថាប័ន ឬអ្នកមានជំនាញក្នុងការគ្រប់គ្រងព្រៃសហគមន៍ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ត្រូវដាក់ស្នើផែនការគ្រប់គ្រងព្រៃសហគមន៍ទៅជូនប្រធានរដ្ឋបាលព្រៃឈើ ដើម្បីធ្វើការពិនិត្យ និងសម្រេចតាមរយៈខណ្ឌរដ្ឋបាលព្រៃឈើ ។

វិធាននៃការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវកំណត់ដោយប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៣០.-**

ផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងព្រៃសហគមន៍ ។

ផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវបានពិនិត្យឡើងវិញដោយរដ្ឋបាលព្រៃឈើរៀងរាល់ប្រាំ(០៥)ឆ្នាំម្តង ឬមុនរយៈពេលនេះប្រសិនបើចាំបាច់ ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ ត្រូវមានការចូលរួមពីតំណាងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ។

រដ្ឋបាលព្រៃឈើអាចតម្រូវឱ្យគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ធ្វើការកែសម្រួលផែនការគ្រប់គ្រងព្រៃសហគមន៍ឡើងវិញឱ្យស្របទៅតាមបទប្បញ្ញត្តិច្បាប់ និងក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា ដើម្បីធានាដល់និរន្តរភាពនៃព្រៃសហគមន៍ ។

## ជំពូកទី ៨

## ប្រភពហិរញ្ញវត្ថុទ្រទ្រង់សហគមន៍ព្រៃឈើ

**មាត្រា ៣១.-**

រដ្ឋបាលព្រៃឈើអាចប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ដើម្បីទ្រទ្រង់ដល់ដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៦២ ៦៣ និងមាត្រា ៦៤ នៃច្បាប់ស្តីពីព្រៃឈើ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ អាចស្វែងរកដោយផ្ទាល់នូវប្រភពហិរញ្ញវត្ថុទ្រទ្រង់ដល់ដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើពីសប្បុរសជន អង្គការជាតិ និងអន្តរជាតិ ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៣២.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

***កន្លែងទទួល***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៤
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ